# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៦០៧

ចុះថ្ងៃទី ០៣-០៧-២០១៥

សាលដីកា

លេខ ៥៥ក្រII "ល"

ចុះថ្ងៃទី ០៦-០៧-២០១៧

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ: នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦-០៧-២០១៤ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍ នាថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧ ដោយមានសមាសភាពដូចខាងក្រោម៖

### សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ

| | | |
|---|---|---|
| លោកស្រី | [redacted] | ជាប្រធានក្រុមប្រឹក្សា |
| លោក | [redacted] | ជាចៅក្រមប្រឹក្សា |
| ឯកឧត្តម | [redacted] | ជាចៅក្រមប្រឹក្សា |

### តំណាងមហាអយ្យការ

| | | |
|---|---|---|
| លោក | [redacted] | ជាព្រះរាជអាជ្ញា |

### ក្រឡាបញ្ជី

| | |
|---|---|
| កញ្ញា | [redacted] |

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៦០៧ ចុះថ្ងៃទី ២៣-០៧-២០១៥ ដែលមាន៖

១-ជនជាប់ចោទឈ្មោះ [redacted] ហៅ [redacted] ភេទប្រុស អាយុ ៥០ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិត្រពាំងសាប ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ ទីលំនៅបច្ចុប្បន្ននៅផ្ទះ១១២ ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted] "ស" មានកូន ៣នាក់ ទោសពីមុនគ្មាន ។ (ដីកាឃុំខ្លួនលេខ ១៦៦៥ ត.ព្រ ថ្ងៃទី០២-០៩-២០១៤)

មានលោក [redacted] ជាមេធាវីការពារសិទ្ធិ។

២-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ៣០ឆ្នាំ ជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើតនៅភូមិតាង៉ក់ ឃុំតាង៉ក់ ស្រុកតាង៉ក់កណ្ដាល ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នមិនពិតប្រាកដ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted] "រ" មានកូន ០១នាក់ ទោសពីមុនគ្មាន ។ (ដីកាឃុំខ្លួនលេខ ១៦៦៦ ត.ព្រ ថ្ងៃទី០២-០៩-២០១៤)

មានលោក [redacted] ជាមេធាវីការពារសិទ្ធិ។





Scanned by CamScanner

ជាប់ចោទពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្ទះលេខ ១១២ ផ្លូវលំ ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០១៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

បណ្តឹងឧទ្ធរណ៍លេខ ៣១២ ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០១៥ របស់ជនជាប់ចោទឈ្មោះ[redacted] ប្តឹងឧទ្ធរណ៍ នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៤១ ក្រ៤ "ផ" ភ.ព.ព្រ.ទ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់សេចក្តីសម្រេចទាំងមូល។

ពាក្យបណ្តឹងឧទ្ធរណ៍លេខ ៣១៤ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ របស់ជនជាប់ចោទឈ្មោះ[redacted]ឹងឧទ្ធរណ៍ នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៤១ ក្រ៤ "ផ" ភ.ព.ព្រ.ទ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់សេចក្តីសម្រេចទាំងមូល។

## ឯរឿងហេតុមានដូចតទៅ

កាលពីថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០១៤ វេលាម៉ោង ១៥ និង០០នាទី នៅចំណុចផ្ទះលេខ ១១២ ផ្លូវលំ ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដោយបានអនុវត្តតាមវិធានញុះញង់ឲ្យលក់ដោយខុសច្បាប់នូវសារធាតុញៀន ក្រុមប្រតិបត្តិការចម្រុះដឹកនាំដោយព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ បានចុះបង្ក្រាបករណីជួញដូរគ្រឿងញៀនខុសច្បាប់ ដោយឃាត់ខ្លួនបានជនសង្ស័យចំនួន ០២នាក់ មានឈ្មោះ [redacted] ហៅ [redacted]ងឈ្មោះ [redacted]មជាមួយវត្ថុតាងថ្នាំញៀនប្រភេទមេតំហ្វេតាមីនទម្ងន់ ១២២៤,០៨ ក្រាម (មួយពាន់ពីររយម្ភៃបួននិងសូន្យប្រាំបីក្រាម) ទូរស័ព្ទដៃចំនួន ២គ្រឿង និងជញ្ជីងថ្លឹងគ្រឿងញៀនចំនួន ០១ គ្រឿង នៅពេលដែលជនសង្ស័យកំពុងធ្វើសកម្មភាពជួញដូរថ្នាំញៀនជាមួយកំលាំងសម្ងាត់របស់សមត្ថកិច្ច។ ក្រោយការសាកសួរជនសង្ស័យឈ្មោះ [redacted] និងឈ្មោះ[redacted]បាននាំឈ្មោះ[redacted]មកផ្ទះរបស់ឈ្មោះ [redacted]ដើម្បីរកទិញគ្រឿងញៀន ក្រោយមកឈ្មោះ[redacted]ារអ្នកលក់ថ្នាំញៀនបានយកគ្រឿងញៀនមកដល់ត្រូវសមត្ថកិច្ចចូលទៅឃាត់ខ្លួនតែម្តង ចំណែកឈ្មោះ[redacted]ឈ្មោះ[redacted]ិងឈ្មោះ[redacted]ាន់រត់គេចមុនពេលសមត្ថកិច្ចចូលទៅបន្ថិច។

*បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១៤១ ក្រ៤ "ផ" ភ.ព.ព្រ.ទ ចុះថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារដូចខាងក្រោម៖*

១-ផ្តន្ទាទោស៖

ក.ឈ្មោះ [redacted] ហៅ [redacted] ភេទប្រុស អាយុ៥០ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ២៧ ឆ្នាំ (ម្ភៃប្រាំពីរឆ្នាំ) និងពិន័យជាប្រាក់ចំនួន ៤០.០០០.០០០ រៀល (សែសិបលានរៀល)

ខ.ឈ្មោះ [redacted]ភេទប្រុស អាយុ ៣០ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ២៧ ឆ្នាំ (ម្ភៃប្រាំពីរឆ្នាំ) និងពិន័យជាប្រាក់ចំនួន ៤០.០០០.០០០ រៀល (សែសិបលានរៀល)



Scanned by CamScanner

ពិបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្ទះលេខ ១១២ ផ្លូវលំ ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០១៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-វត្ថុតាងចាប់យក៖ ក្នុងកំណត់ហេតុទទួលវត្ថុចាប់យកពីចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ លេខ ៦០៨ វ.ត ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៤ មាន៖

ក. ស្រោមសំបុត្រពណ៌គគីបិទជិតចំនួន ០១ មានហត្ថលេខាសមត្ថកិច្ច និងមានស្នាមមេដៃរបស់ជនជាប់ចោទ។ នៅលើស្រោមសំបុត្រសរសេរថាៈ កញ្ចប់វត្ថុតាងគ្រឿងញៀនប្រភេទម្សៅពណ៌សទម្ងន់ ១២២៤,០៨ ក្រាម( មួយពាន់ពីររយម្ភៃបួនក្បៀសសូន្យប្រាំបីក្រាម) មានភាពសុទ្ធស្មើ៖

$$\frac{1224{,}08 \text{ ក្រាម} \times 28.65}{100} = \text{៣៥០,៦៩ ក្រាម}$$

-ជញ្ជីងម៉ាក Capacity 500g x0,01g ចំនួន ០១គ្រឿង។

-ថង់ប្លាស្ទិកសម្រាប់ច្រកគ្រឿងញៀនមួយចំនួន។

ត្រូវរឹបអូសបំផ្លាញចោលតាមមាត្រា ៩៣, ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ. ប្រាក់ខ្មែរចំនួន ៦០០០០រៀល (ប្រាំមួយម៉ឺនរៀល)

-ទូរស័ព្ទម៉ាកណូគា ១២៨០ ពណ៌ខ្មៅ ០១គ្រឿង

-ទូរស័ព្ទម៉ាកណូគា សេ២ ពណ៌ស ០១ គ្រឿង

ត្រូវប្រគល់ឱ្យម្ចាស់ដើមវិញតាមមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៥ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារសិទ្ធិជនជាប់ចោទ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥។

បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

បានឃើញ របាយការណ៍រឿងព្រហ្មទណ្ឌ ចុះថ្ងៃទី ២១-១០-២០១៥ របស់សាលាឧទ្ធរណ៍ ។

បានឃើញ សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី ២២-១១-២០១៦ របស់មហាអយ្យការអមសាលាឧទ្ធរណ៍។

បានឃើញ ដីកាចាត់តាំងសមាសភាពក្រុមប្រឹក្សាជំនុំជម្រះទី២លេខ ២៩ ដក១០១៦ ចុះថ្ងៃទី ១០-១១-២០១៦។

## នាពេលសវនាការ

-ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបរឿង

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា ខ្លួនរៀនបានដល់ថ្នាក់ទី៥ចាស់ មានកូន៤នាក់ ។ ខ្លួនមិនធ្លាប់មានទោសទេ។ ខ្លួនប្តឹងឧទ្ធរណ៍ដោយសារតែទោសដែលសាលាដំបូងសម្រេចផ្តន្ទាទោសខ្លួននោះវាធ្ងន់ពេក ហើយខ្លួនមានជំងឺលើសឈាម ជំងឺទឹកនោមផ្អែម និងឡើងអាស៊ីត។ ខ្លួនមិនបានលក់ថ្នាំញៀនទេ ខ្លួនគ្រាន់តែបានហូបបាយជាមួយគេ។ ចម្លើយដែលខ្លួនឆ្លើយសារភាពនៅប៉ូលីស និងនៅចៅក្រមស៊ើបសួរដោយសារតែខ្លួនខ្លាចគេធ្វើទារុណកម្មខ្លួន និងខ្លួនភ័យពេក ដូច្នេះខ្លួនសូមបដិសេធចម្លើយនៅដំណាក់កាលប៉ូលីស និងចៅក្រមស៊ើបសួរ។ គ្រឿងញៀននេះបាននៅផ្ទះខ្លួនដោយសារតែឈ្មោះ [redacted] បានមកហូបបាយ និងប៊ីយ៉ានៅផ្ទះខ្លួនទើបមានគ្រឿងញៀននេះ។ គេមិនបានប្រាប់ខ្លួនថាគេជួញដូរថ្នាំញៀនទេ គេគ្រាន់តែសុំផ្ទះរបស់ខ្លួនស៊ីផឹក ហើយគេ



Scanned by CamScanner

ថានឹងឱ្យកម្រៃខ្លួនខ្លះ។ ខ្លួនបានស្គាល់ឈ្មោះ [redacted] ពេលថ្មីៗនេះទេ។ ឈ្មោះ [redacted] ជាអ្នកចង់ទិញថ្នាំញៀន ហើយខ្លួនក៏ទាក់ទងទៅឈ្មោះ [redacted] ព្រោះឈ្មោះ [redacted] ធ្លាប់ប្រាប់ខ្លួនថាបើមានគេចង់ទិញថ្នាំញៀនឱ្យទាក់ទងទៅគេ។ ឈ្មោះ [redacted] រួមជាមួយឈ្មោះ [redacted] និងឈ្មោះ [redacted] សំណូមពរឱ្យតុលាការសម្រេចឱ្យខ្លួនមានសេរីភាពឡើងវិញ។

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា ខ្លួនជាអ្នកបកប្រែភាសាចិន មិនធ្លាប់មានទោសពីមុនមកទេ ខ្លួនមានកូនម្នាក់។ ខ្លួនប្តឹងឧទ្ធរណ៍ដោយសារតែខ្លួនមិនពាក់ព័ន្ធជាមួយរឿងក្តីនេះទេ។ គេឃាត់ខ្លួនៗនៅផ្ទះរបស់ឈ្មោះ [redacted] ដោយសារខ្លួនបានទៅជាមួយឈ្មោះ [redacted] ខ្លួនទៅលេងផ្ទះឈ្មោះ [redacted] ដោយសារមានការហូបចុកជុំគ្នា។ ពេលគេចាប់ខ្លួនៗនៅក្នុងបន្ទប់គឺគ្មានគ្រឿងញៀនទេ។ ខ្លួនជាអ្នកនាំឈ្មោះ [redacted] ទៅទិញថ្នាំញៀនពីឈ្មោះ [redacted] ដោយគ្រាន់តែបានកម្រៃជើងសារចំនួន ៣០០ដុល្លារ ពីការនាំភ្ញៀវនេះ ខ្លួនមិនធ្លាប់នាំគេទៅទិញថ្នាំញៀនពីមុនមកទេ នេះគឺជាលើកទី១ ហើយមិនទាន់បានលុយទេ។ អ្នកដែលសន្យាថាឱ្យខ្លួន៣០០$នោះគឺជាស្ត្រីម្នាក់ដែលជាកម្លាំងរបស់សមត្ថកិច្ច។ ខ្លួនដឹងកំហុសហើយ សូមតុលាការសម្រេចបន្ធូរបន្ថយទោសឱ្យខ្លួនផង ដោយធ្វើការកែប្រែបទចោទប្រកាន់ពីបទជួញដូរដោយខុសច្បាប់មកជាបទកម្រៃជើងសារវិញ។

-តំណាងមហាអយ្យការសន្និដ្ឋានថា ក្រោយពិភាក្សាដេញដោលឃើញថា ចម្លើយរបស់ជនជាប់ចោទទាំងពីរហាក់មានភាពលាក់លៀមមិនច្បាស់លាស់ តែទោះយ៉ាងណាអំពើរបស់ជនជាប់ចោទទាំងពីរគឺជាបទល្មើសជាក់ស្តែងដោយបានឃាត់ខ្លួនជនជាប់ចោទទាំងពីរជាមួយនឹងវត្ថុតាង។ តំណាងមហាអយ្យការយល់ឃើញថា សាលក្រមរបស់សាលាដំបូងដែលសម្រេចមកនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ សូមក្រុមប្រឹក្សាសម្រេចតម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការដដែល។

-លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សេចក្តីសន្និដ្ឋានថា មុនដំបូងកូនក្តីរបស់ខ្លួនឆ្លើយមានភាពលាក់លៀម ប៉ុន្តែក្រោយមកគាត់បានឆ្លើយសារភាព ក្នុងរឿងក្តីនេះកូនក្តីខ្លួនទើបតែប្រព្រឹត្តជាលើកទីមួយ។ គាត់ប្រព្រឹត្តអំពើនេះគឺដើម្បីបានកម្រៃជើងសារបន្តិចបន្តួចដើម្បីផ្គត់ផ្គង់ជីវភាពដោយសារតែជីវភាពក្រីក្រ ជាងនេះទៅទៀត កូនក្តីខ្លួនមានមុខរបរត្រឹមត្រូវ សូមក្រុមប្រឹក្សាសម្រេចបន្ធូរបន្ថយទោសឱ្យកូនក្តីខ្លួនផង។

-លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនបានឆ្លើយបដិសេធនៅសាលាដំបូងរួចហើយ ដោយគាត់បានបញ្ជាក់ថា ឈ្មោះ [redacted] និងឈ្មោះ [redacted] ដែលធ្លាប់ធ្វើទាហានជាមួយគ្នាបានសុំផ្ទះរបស់គាត់ដើម្បីហូបចុកជុំគ្នា។ ឈ្មោះ [redacted] មិនបានប្រាប់អំពីគ្រឿងញៀនទេដោយគ្រាន់តែថាសុំកន្លែងស៊ីផឹក តែឈ្មោះ [redacted] នេះគឺជាកម្លាំងរបស់សមត្ថកិច្ច ហេតុនេះសកម្មភាពរបស់សមត្ថកិច្ចនេះមិនមែនជាវិធានញុះញង់ទេ តែជាការរៀបចំអន្ទាក់ហើយទម្លាក់កំហុសឱ្យកូនក្តីខ្លួន។ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទក៏ដូចជាក្រុមគ្រួសាររបស់ជនជាប់ចោទពិតជាចង់ឃើញជនជាប់ចោទបានចំណាយ



Scanned by CamScanner

ពេលចុងក្រោយនៃជីវិតរបស់គាត់នៅខាងក្រៅពន្ធនាគារដោយហេតុថាពេលនេះជនជាប់ចោទមានវ័យចំណាស់ណាស់ទៅហើយ។ សំណូមពរឱ្យក្រុមប្រឹក្សាសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់។

*ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ*

*ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ*

*ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ*

*ក្រោយពីបានពិចារណាលើគ្រប់ឯកសារ និងភស្តុតាងផ្សេងៗ*

*ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ*

## សាលាឧទ្ធរណ៍

## យល់ឃើញថា

១- បណ្តឹងឧទ្ធរណ៍លេខ ៣១២ ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០១៥ របស់ជនជាប់ចោទឈ្មោះ [redacted] ប្តឹងឧទ្ធរណ៍ នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៤១ ក្រ៤ "ផ" ភ.ព.ព្រ.ទ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់សេចក្តីសម្រេចទាំងមូល។ បណ្តឹងនេះធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍អាចលើករឿងនេះដើម្បីជំនុំជម្រះបាន យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២- បណ្តឹងឧទ្ធរណ៍លេខ ៣១៤ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ របស់ជនជាប់ចោទឈ្មោ[redacted] ប្តឹងឧទ្ធរណ៍ នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៤១ ក្រ៤ "ផ" ភ.ព.ព្រ.ទ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់សេចក្តីសម្រេចទាំងមូល។ បណ្តឹងនេះធ្វើឡើងក្នុងកំណត់ច្បាប់សាលាឧទ្ធរណ៍អាចលើករឿងនេះដើម្បីជំនុំជម្រះបាន យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣- ជនជាប់ចោទឈ្មោះ [redacted]នឆ្លើយថាខ្លួនមិនបានជួញដូរថ្នាំញៀនទេ គឺឈ្មោ[redacted]ដែលជាមិត្តភក្តិបានប្រាប់ថាចង់ទិញថ្នាំញៀនខ្លួនក៏ទាក់ទងឈ្មោះ [redacted] ពេលប៉ូលីសចាប់គឺឈ្មោះ[redacted] ថាសុំផ្ទះខ្លួនហូបបាយហើយគេមិនឱ្យខ្លួនសួរនាំទេ ដោយគ្រាន់តែប្រាប់ថាចាំគេឱ្យខ្លួនចាយខ្លះ ខ្លួនមិនដឹងថាគេជួញដូរថ្នាំញៀននៅផ្ទះខ្លួនទេ។ ក្រុមប្រឹក្សាយល់ឃើញថា បើទោះបីជាជនជាប់ចោទបានឆ្លើយបដិសេធថាមិនបានប្រព្រឹត្តដូចការចោទប្រកាន់ គ្រាន់តែជាចម្លើយដោះសារតែប៉ុណ្ណោះ ដោយហេតុថាបទល្មើសនេះគឺជាបទល្មើសជាក់ស្តែងដោយបានសមត្ថកិច្ចបានប្រើវិធានការណ៍ញុះញង់ឱ្យលក់ ហើយសមត្ថកិច្ចចាប់បានវត្ថុតាងនៅផ្ទះរបស់ជនជាប់ចោទ និងឃាត់ខ្លួនជនជាប់ចោទនៅពេលប្រព្រឹត្តតែម្តង។ ជាងនេះទៅទៀត ជនជាប់ចោទបានឆ្លើយសារភាពនៅចំពោះមុខសមត្ថកិច្ច ចំពោះមុខអយ្យការ និងនៅចំពោះមុខចៅក្រមស៊ើបសួរថាខ្លួនពិតជាប្រព្រឹត្ត



Scanned by CamScanner

នូវការចោទប្រកាន់ ដែលចម្លើយទាំងនេះស៊ីសង្វាក់គ្នាទៅនឹងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងភស្តុតាងនានាក្នុងសំណុំរឿងអាចឱ្យក្រុមប្រឹក្សាជឿបានថាជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់មែន ។

៤- ជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយថាខ្លួនពិតជាបាននាំឈ្មោះ ផល ទៅទិញគ្រឿងញៀនពីឈ្មោះ ថា ដោយគេសន្យាថានឹងឱ្យប្រាក់កម្រៃជើងសារខ្លួនចំនួន ៣០០ដុល្លារ តែមិនទាន់បានថ្លៃសេវាផងក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនបាន។ ក្រុមប្រឹក្សាយល់ឃើញថា ជនជាប់ចោទឈ្មោះ[redacted]នេះពិតជាពាក់ព័ន្ធនិងការរកស៊ីជួញដូរគ្រឿងញៀននេះប្រាកដមែន ដោយជនជាប់ចោទបាននាំអ្នកទិញគ្រឿងញៀនឱ្យមកទិញគ្រឿងញៀន ពីអ្នកលក់ថ្នាំញៀន ដែលចម្លើយរបស់ជនជាប់ចោទស៊ីសង្វាក់ទៅនឹងអង្គហេតុ និងភស្តុតាងនានាក្នុងសំណុំរឿងអាចឱ្យក្រុមប្រឹក្សាជឿបានថាជនជាប់ចោទឈ្មោះ[redacted]ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន។

៥-ក្រុមប្រឹក្សាយល់ឃើញថា អំពើរបស់ជនជាប់ចោទឈ្មោះ[redacted]និងឈ្មោះ[redacted]ជាបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមបញ្ញត្តមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៦-ក្រុមប្រឹក្សាយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ទើបតែប្រព្រឹត្តបទល្មើសជាលើកទីមួយដោយសារតែជីវភាពក្រីក្រ ហើយមានជំងឺប្រចាំកាយ ដូចក្នុងលិខិតបញ្ជាក់សុខភាពលេខ ១៥៥២ ម១. ចុះ ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៦ និងការប្រព្រឹត្តបទល្មើសនេះមិនទាន់បានបង្កព្យសនកម្មដល់សង្គមនៅឡើយ។ ជាងនេះទៅទៀត ទម្ងន់សុទ្ធនៃគ្រឿងញៀនមានចំនួន ៣៥០,៦៩ក្រាម ដែលមានចំនួនលើសកម្រិត ២៤០ក្រាម តិចតួច ដែលទម្ងន់ ២៤០ក្រាមនេះត្រូវផ្តន្ទាទោស១០ ទៅ២០ឆ្នាំ។ ហេតុដូច្នេះ ក្រុមប្រឹក្សាគប្បីធ្វើការបន្ធូរបន្ថយទោសតាមទំហំនៃការប្រព្រឹត្ត និងព្យសនកម្មដែលបានបង្កដោយសារបទល្មើស ។

៧-ក្រុមប្រឹក្សាយល់ឃើញថា ជនជាប់ចោទឈ្មោះ[redacted] ទើបតែប្រព្រឹត្តបទល្មើសជាលើកទី១ ដោយសារតែជីវភាពក្រីក្រ ដោយសង្ឃឹមថានឹងបានប្រាក់កម្រៃជើងសារចំនួន ៣០០ ដុល្លារអាមេរិក ពីការនាំភ្ញៀវទៅទិញថ្នាំញៀននេះ ហើយការប្រព្រឹត្តបទល្មើសនេះមិនទាន់បានបង្កព្យសនកម្មដល់សង្គមនៅឡើយ។ ជាងនេះទៅទៀត ទម្ងន់សុទ្ធនៃគ្រឿងញៀនមានចំនួន ៣៥០,៦៩ក្រាម ដែលមានចំនួនលើសកម្រិត ២៤០ក្រាម តិចតួច ដែលទម្ងន់ ២៤០ក្រាមនេះត្រូវផ្តន្ទាទោស១០ ទៅ២០ឆ្នាំ។ ហេតុដូច្នេះ ក្រុមប្រឹក្សាគប្បីធ្វើការបន្ធូរបន្ថយទោសតាមទំហំនៃការប្រព្រឹត្ត និងព្យសនកម្មដែលបានបង្កដោយសារបទល្មើស ។



Scanned by CamScanner

៨-សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងមហាអយ្យការថា ក្រោយពិភាក្សាដេញដោលឃើញថា ចម្លើយរបស់ជនជាប់ចោទទាំងពីរហាក់មានភាពលាក់លៀមមិនច្បាស់លាស់ តែទោះយ៉ាងណាអំពើរបស់ជនជាប់ចោទទាំងពីរ គឺជាបទល្មើសជាក់ស្តែងដោយបានឃាត់ខ្លួនជនជាប់ចោទទាំងពីរជាមួយនឹងវត្ថុតាង។ តំណាងមហាអយ្យការយល់ឃើញថាសាលក្រមរបស់សាលាដំបូងដែលសម្រេចមកនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ សូមក្រុមប្រឹក្សាសម្រេចតម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការដដែល។ ក្រុមប្រឹក្សាយល់ឃើញថា ការស្នើសុំឱ្យតម្កល់សាលក្រមនេះមានលក្ខណៈត្រឹមត្រូវហើយទាក់ទងនឹងពិរុទ្ធភាពលើជនជាប់ចោទ តែទាក់ទងនឹងទោសដែលបានប្រកាសលើជនជាប់ចោទគឺមានលក្ខណៈធ្ងន់ធ្ងរដែលគប្បីបន្ធូបន្ថយទោសខ្លះដល់ជនជាប់ចោទទាំងពីរដូចការលើកឡើងក្នុងចំណុចទី៦ និង៧ នៃសំអាងហេតុខាងលើ។

៩-លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សេចក្តីសន្និដ្ឋានថា មុនដំបូងកូនក្តីរបស់ខ្លួនឆ្លើយមានភាពលាក់លៀម ប៉ុន្តែក្រោយមកគាត់បានឆ្លើយសារភាព ក្នុងរឿងក្តីនេះកូនក្តីខ្លួនទើបតែប្រព្រឹត្តជាលើកទីមួយ។ គាត់ប្រព្រឹត្តអំពើនេះគឺដើម្បីបានកម្រៃដើងសារបន្តិចបន្តួចដើម្បីផ្គត់ផ្គង់ជីវភាពដោយសារតែជីវភាពក្រីក្រ ជាងនេះទៅទៀត កូនក្តីខ្លួនមានមុខរបរត្រឹមត្រូវ សូមក្រុមប្រឹក្សាសម្រេចបន្ធូរបន្ថយទោសឱ្យកូនក្តីខ្លួនផង។ ក្រុមប្រឹក្សាយល់ឃើញថា ការស្នើសុំនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ផ្អែកតាមកាលៈទេសៈនៃការប្រព្រឹត្តបទល្មើស និងបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ គប្បីក្រុមប្រឹក្សាលើកយកមកពិចារណា។

១០-លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនបានឆ្លើយបដិសេធនៅសាលាដំបូងរួចហើយដោយគាត់បានបញ្ជាក់ថា ឈ្មោះ [redacted] និងឈ្មោះ [redacted] ដែលធ្លាប់ធ្វើទាហានជាមួយគ្នាបានសុំផ្ទះរបស់គាត់ដើម្បីហូបចុកជុំគ្នា។ ឈ្មោះ [redacted] មិនបានប្រាប់អំពីគ្រឿងញៀនទេដោយគ្រាន់តែថាសុំកន្លែងស៊ីផឹក តែឈ្មោះ [redacted] នេះគឺជាកម្លាំងរបស់សមត្ថកិច្ច ហេតុនេះសកម្មភាពរបស់សមត្ថកិច្ចនេះមិនមែនជាវិធានញុះញង់ទេ តែជាការរៀបចំអន្ទាក់ហើយទម្លាក់កំហុសឱ្យកូនក្តីខ្លួន។ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទក៏ដូចជាក្រុមគ្រួសាររបស់ជនជាប់ចោទ ពិតជាចង់ឃើញជនជាប់ចោទបានចំណាយពេលចុងក្រោយនៃជីវិតរបស់គាត់នៅខាងក្រៅពន្ធនាគារដោយហេតុថាពេលនេះជនជាប់ចោទមានវ័យចំណាស់ណាស់ទៅហើយ។ សំណូមពរឱ្យក្រុមប្រឹក្សាសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់។ ក្រុមប្រឹក្សាយល់ឃើញថា សេចក្តីសន្និដ្ឋាននេះមិនត្រឹមត្រូវទេ ដោយហេតុថា ជនជាប់ចោទបានឆ្លើយសារភាពនៅចំពោះមុខសមត្ថកិច្ច ដំណាក់កាលអយ្យការ និងចៅក្រមស៊ើបសួរថា ខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន បើទោះបីជា ក្រោយមកជនជាប់ចោទបានកែប្រែចម្លើយក៏ដោយ តែការកែប្រែចម្លើយនេះមិនមានភស្តុតាងដោះបន្ទុកដែលអាចឱ្យក្រុមប្រឹក្សាលើកយកមកពិចារណាបានឡើយ។

១១-ក្រុមប្រឹក្សាយល់ឃើញថា សាលក្រមព្រហ្មទណ្ឌលេខ ១៤១ ក្រ៤ "ផ"ភ.ព.ព្រ.១ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលសម្រេចដោយលើកសំអាងហេតុមកនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់រួចហើយ លើកលែងតែចំណុចនៃការផ្តន្ទាទោសលើជនជាប់ចោទទាំងពីរ គប្បីធ្វើការកែប្រែតាមការយល់ឃើញខាងលើ ។



Scanned by CamScanner

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដី

១-ទទួលបណ្ដឹងឧទ្ធរណ៍លេខ ៣១២ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ២០១៥ របស់ជនជាប់ចោទឈ្មោះ [redacted] ទុកជាត្រឹមត្រូវតាមទម្រង់ និងអង្គច្បាប់ខ្លះ ។

២-ទទួលបណ្ដឹងឧទ្ធរណ៍លេខ ៣១៥ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ២០១៥ របស់ជនជាប់ចោទឈ្មោះ [redacted] ទុកជាត្រឹមត្រូវតាមទម្រង់ និងអង្គច្បាប់ខ្លះ ។

៣-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១១៩១ ក្រ៤ "អ"ក.ព.ប្រ.ឋ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការមួយផ្នែក លើកលែងតែចំណុចនៃការផ្ដន្ទាទោសជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] ក្នុងម្នាក់ៗចំនួន ១៧ឆ្នាំ (ដប់ប្រាំពីរឆ្នាំ) ត្រូវកែប្រែមកជា "ផ្ដន្ទាទោសជនជាប់ចោទឈ្មោះ [redacted]ៅ ចូ ភេទប្រុស អាយុ ៥០ឆ្នាំ ជនជាតិខ្មែរ និងជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ចំនួន ១២(ដប់ពីរ)ឆ្នាំ វិញ"។

៤-បង្គាប់ឱ្យឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] តាមនីតិវិធីច្បាប់ ។

៥-សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted]

បើកសិទ្ធិប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

ក្រឡាបញ្ជី

[redacted]



Scanned by CamScanner